អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2018, 13:28
CMS/CFO: Sann Rada

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| **កែលើឯកសារលេខ៖** | **ERN(s):** | **កាលបរិច្ឆេទ៖** | **ប្រភេទកំណែ៖** |
|---|---|---|---|
| E3/2797 | 01169255-01169270 | 22/01/2018 | ☐ កែលើឯកសារដើម<br>☒ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

**មូលហេតុនៃការកែតម្រូវ៖**

ជំនួសឯកសារមិនទាន់កែតម្រូវដោយឯកសារដែលបានកែតម្រូវរួច។

**សេចក្ដីលម្អិតនៃការកែតម្រូវ៖**

ស្នើដោយ៖ អង្គភាពបកប្រែភាសា ហត្ថលេខា៖

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

៤១

Deleted: Non revised version, portion(s) of this document will be revised by ITU upon request.¶

Original EN: 00143676-00143687

ឈ្មោះឯកសារ៖ ស្រេង.00១

ជ ឆាន ហៅ ស្រេង

Deleted: ជៅ ឆាន់

"សកម្មភាពក្រោយថ្ងៃ ១៧ មេសា ១៩៧៥"

[ឯកសារសរសេរដៃចំនួន ២៨ ទំព័រ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ នៅខាងដើម និងចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ នៅចុងបញ្ចប់]

[ទំព័រ ១]

បន្ទាប់ពីការរំដោះទូទាំងប្រទេស ធុច ត្រូវបានចាត់តាំងឱ្យមកគ្រប់គ្រងក្រសួងពាណិជ្ជកម្ម។ ឌឿន បានត្រៀមខ្លួនជាស្រេចដើម្បីមកនៅការិយាល័យ ៨៧០។ ធុច បានកោះប្រជុំគណៈកម្មាធិការនៅក្នុងផ្ទះដែលគាត់មកគ្រប់គ្រងក្រសួងពាណិជ្ជកម្មនៅទីក្រុងភ្នំពេញ។ អ្នកនៅទីនោះរួមមាន៖

១. ឌឿន

២. ស្រេង

៣. សុត

៤. ឆិន

៥. តុល

៦. ជីម ឬ ឈឿន

Deleted: ជឿ

ធុច បាននិយាយលើកទឹកចិត្តពួកយើង។ គាត់ថា ឥឡូវនេះ បក្សកុម្មុយនីស្តបានឈ្នះហើយ។ តើវាផ្តល់រំលំនរណា? វាផ្តួលរំលំតែពួកសាធារណរដ្ឋ លន់ នល់ តែប៉ុណ្ណោះ។ តាមពិតទៅ វាមិនបានផ្តួលរំលំចលនារបស់យើងទេ។ ផ្ទុយមកវិញ ចលនារបស់យើងបានរីកលូតលាស់ និងរីកចម្រើនកាន់តែច្រើនឡើង។ ស្ថានភាពកាន់តែអំណោយផលសម្រាប់យើង ហើយមានលក្ខខណ្ឌដើម្បីទទួលបានជ័យជម្នះទាំងនៅក្នុងរយៈពេលភ្លាមៗ និងនៅក្នុងរយៈពេលវែង។ ធុច បានលើកឡើងពីបញ្ហាមួយចំនួនដើម្បីបង្ហាញពីរឿងនេះ។

កម្លាំងស្នូលសំខាន់របស់យើងត្រូវចាត់ឲ្យកាន់មុខងារសំខាន់ៗកាន់តែច្រើន មានន័យថា ពួកគេកំពុងឡើងកាន់តែខ្ពស់ទៅក្នុងជួរថ្នាក់ដឹកនាំ។

យើងក៏កាន់កាប់កម្លាំងយោធា ដែលបោះជំរំនៅកន្លែងដែលក្បាលម៉ាស៊ីនដឹកនាំជាតិត្រូវឈរជើងផងដែរ...

Deleted: Non revised version, portion(s) of this document will be revised by ITU upon request.

Original EN: 00143676-00143687

សមមិត្តរបស់យើងនៅភូមិភាគនេះកំពុងទទួលតំណែងសំខាន់ៗកាន់តែច្រើននៅភូមិភាគនេះ ដែលធ្វើស្ថានភាពកាន់តែងាយសម្រាប់យើង និងលំបាកសម្រាប់នរណាដែលចង់ធ្វើអីយើង។ លើសពីនេះ តំបន់សៀមរាប-ឧត្តរមានជ័យ [ទំព័រ ២] នឹងត្រូវអង្គការរៀបចំឡើងវិញនៅប៉ុន្មានថ្ងៃទៀតឲ្យក្លាយជាតំបន់ឯករាជ្យមួយ ហើយ សុត ឈរជើងនៅទីនោះ។ នេះជាការល្អសម្រាប់យើង សម្រាប់យុទ្ធសាស្ត្រយើង។ ដូចគ្នានេះផងដែរ កម្លាំងយើងមិនមែនមានតែនៅក្នុងភូមិភាគយើងទេ។ មានកម្លាំងនៅក្នុងភូមិភាគផ្សេងទៀត ទោះបីជាយើងមិនទាន់ត្រូវការដឹងច្រើនអំពីរឿងនេះក៏ដោយ ដោយសារវាអាចនាំឲ្យបែកការណ៍។ ទោះបីជាតាមពិតទៅកងកម្លាំងសេអ៊ីអានាំមុខនៅក្នុងរបបសាធារណរដ្ឋត្រូវបានខ្ចាត់ខ្ចាយ ហេតុនេះ យើងបាត់បង់បណ្ដាញមួយក៏ដោយ ក៏យើងនៅតែមានបណ្ដាញផ្សេងទៀតក្នុងទម្រង់ជាខ្សែរយៈសម្ងាត់ដែលជារបស់យើងនៅថ្នាក់ខ្ពស់ដែលមាននៅក្នុងថ្នាក់ដឹកនាំបក្ស។ ពួកគេក៏នៅតែមានទំនាក់ទំនងជាមួយពួកខាងកើត។ (ត្រង់នេះ គាត់សំដៅទៅលើយ៉ា (នៃភូមិភាគឦសាន) បើទោះបីជានៅពេលនេះគាត់មិនទាន់បានប្រកាសរឿងនេះក៏ដោយ)។ នៅពេលដែលគាត់និយាយពីចំណុចនេះ មហាជនសួរថាតើក្រុមរបស់យើងបង្កើតជាកម្លាំងប្រភេទណា។ នេះគឺដោយសារយើងជាភ្នាក់ងារសេអ៊ីអា ដូច្នេះតើយើងអាចមានទំនាក់ទំនងជាមួយនឹងពួកខាងកើតបែបណាទៅ? ធុច សើចហើយនិយាយថារឿងទាំងនេះគឺជារឿងតែមួយ ហើយដូចតែគ្នាទេ។ រឿងសំខាន់គឺត្រូវធ្វើគ្រប់យ៉ាងឲ្យតែយើងផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជាបាន។ តម្រូវការរបស់យើងឥឡូវនេះគឺថា ពេលដែលយើងធ្វើ_សកម្មភាព ពួកគេនឹងជួយគាំទ្រពួកយើង អាចក្នុងរយៈពេលភ្លាមៗ ឬក្នុងរយៈពេលវែង។

យើងទាំងអស់គ្នាបានដឹងរួចទៅហើយអំពីបញ្ហានៃជ័យជម្នះ និងបរាជ័យ។ ទោះបីជាមាគ៌ាសកម្មភាពយើងគឺថា បើមានលទ្ធភាពសម្រាប់ការទទួលជ័យជម្នះភ្លាមៗ យើងចាំបាច់ត្រូវធ្វើសកម្មភាព ប៉ុន្តែបើកាលៈទេសៈមិនអំណោយផល យើងត្រូវធ្វើការរៀបចំសម្រាប់រយៈពេលវែង។ សារៈសំខាន់នៃរឿងនេះគឺត្រូវកែប្រែខ្លួនយើងទាំងស្រុងឲ្យស្របតាមមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា ចំណែកឯនៅពេលដែលយើងបន្តការអនុវត្តជាក់_ស្តែងនៅតាមមូលដ្ឋាន គឺអាស្រ័យលើអ្វីដែលយើងអាចធ្វើបាន។ ទោះយ៉ាងណា យើងពិតជាមានផែនការរបស់យើង ដែលគឺថា ចាំបាច់ត្រូវយកឈ្នះយ៉ាងឆាប់រហ័ស ព្រោះបើយើងបណ្តោយឲ្យស្ថានភាពនេះបន្តក្នុងរយៈពេលយូរ នោះវានឹងកាន់តែអាក្រក់ទៅសម្រាប់យើង។

[ទំព័រ ៣]

បន្ទាប់ពីសន្ទនាបានបន្តិច ធុច បានស្នើឲ្យយើងដាក់បញ្ចូលគ្នានូវសំណុំតួនាទីថ្មីនៅមូលដ្ឋាននីមួយៗ ដែលស្របនឹងស្ថានភាពថ្មី ខណៈពេលប្រើប្រាស់តួនាទីដើមផងដែរ។

**Deleted:** Non revised version, portion(s) of this document will be revised by ITU upon request.¶

Original EN: 00143676-00143687

<u>នៅភូមិភាគឧត្តរ ដែលតួនាទីទាំងនេះរួមមាន៖</u>

១. ស្រេង ជាប្រធាន គ្រប់គ្រងតំបន់ ៤១

២. ធិន ជាអនុប្រធាន គ្រប់គ្រងតំបន់ ៤៣

៣. តុល ជាសមាជិក គ្រប់គ្រងតំបន់ ៤២

៤. ហាស់ គ្រប់គ្រងយោធាភូមិភាគឧត្តរ។

<u>តំបន់ ១០៦៖</u>

១. សុត ជាប្រធាន

២. ឃឿន ជាអនុប្រធាន

៣. ស៊ាន ជាសមាជិក

៤. ប៉េង គ្រប់គ្រងកងទ័ពតំបន់ ១០៦។

ដោយឡែកសម្រាប់ខ្លួនគាត់ គាត់នៅតែគ្រប់គ្រងរួមដដែលដូចពីមុន និងរក្សាក្រុមរបស់គាត់នៅកងពលធំភូមិភាគឧត្តរដែលត្រូវអង្គការបញ្ជា។

ខឿន គឺជាករណីពិសេស ចំណុចសំខាន់គឺគាត់នៅក្នុងការិយាល័យ ៨៧០។ ទោះយ៉ាងណា ការងារប្រចាំរបស់គាត់គឺត្រូវយកទិន្នន័យពីការិយាល័យ ៨៧០ ស្ដីពីវិធានការណាមួយដែលគេអាចប្រើប្រឆាំងនឹងពួកយើង។

គណៈកម្មាធិការដឹកនាំរួមរួមមាន៖

១. ធុច ជាប្រធាន ដូចពីមុន

២. ខឿន ជាអនុប្រធាន

៣. ស្រេង ជាសមាជិក

៤. សុត ជាសមាជិក។

ទំនាក់ទំនងក្នុងចំណោមពួកយើងត្រូវរក្សាជាការសម្ងាត់តាមដែលអាចធ្វើទៅបាន។

[ទំព័រ ៤]

បន្ទាប់មក មានការបង្ហាញពីតួនាទី និងភារកិច្ចជាក់លាក់។

១. ធ្វើការរៀបចំដើម្បីកសាង ពង្រឹង និងពង្រីកអំណាចយើងដើម្បីឲ្យមាននៅគ្រប់ទីកន្លែងតាមរយៈអំណាចរដ្ឋបដិវត្តន៍ទាំងមូល។ នេះគឺជាគោលការណ៍រួម ប៉ុន្តែរឿងសំខាន់គឺជួរមន្ត្រីជាន់ខ្ពស់នៃថ្នាក់ដឹកនាំ។

**Deleted:** Non revised version, portion(s) of this document will be revised by ITU upon request.¶

Original EN: 00143676-00143687

២. ធ្វើការរៀបចំត្រៀមនូវការផ្គត់ផ្គង់ស្បៀងគ្រប់ប្រភេទ ក្នុងនោះរួមមានស្រូវ អង្ករ និងអំបិល។
៣. កសាងជួរមន្ត្រីកងទ័ពនៅក្នុងគ្រប់ទីតាំង ហើយបើមានលទ្ធភាព ក៏ចាំបាច់ត្រូវដាក់បញ្ចូលគ្នានូវកងកម្លាំងពិសេសដែលជារបស់យើង ទោះបីជាពួកគេមានចំនួនតិចក៏ដោយ ឲ្យតែស្ថិតក្រោមមនោគមវិជ្ជា និងការគ្រប់គ្រងនយោបាយទាំងស្រុងរបស់យើង។
៤. ភារកិច្ចបន្ទាប់បន្ថែមតម្រូវឱ្យដាក់បញ្ចូលគ្នា [សន្តិសម្ព័ន្ធ] នូវកងកម្លាំងដើម្បីធ្វើការឃាយីគ្រប់រូបភាពនៅមូលដ្ឋាននីមួយៗ ទៅតាមលទ្ធភាពរបស់ពួកគេ ...

គោលការណ៍ទាំងនេះត្រូវបានជំរុញនៅចុងឆ្នាំ ១៩៧៥។

គ្រប់គ្នាបានផ្តល់មតិ។ ការមូលមតិគ្នាគឺថា ចាំបាច់ត្រូវបន្តអនុវត្តផែនការ តែមានការលំបាកជាច្រើន។ ឧទាហរណ៍ គឺមានបញ្ហារឿងអង្ករ។ បើរឿងនេះត្រូវដោះស្រាយដោយមូលដ្ឋាន វានឹងមានការលំបាកគួរឱ្យខ្លាច ដោយសារតែពួកគេគ្មានអ្វីហូបអស់មួយរដូវវស្សារួចទៅហើយ ហើយស្រូវដែលកំពុងប្រមូលផលនៅពេលនេះនឹងអស់ជាបន្តបន្ទាប់ ដែលធ្វើឱ្យគ្មានសល់ស្រូវដើម្បីធ្វើការរៀបចំទេ។ រឿងសំខាន់អំពីបញ្ហាកងទ័ពគឺថា ធុច ឈរជើងនៅកន្លែងដែលកងពលធំចាស់ៗឈរជើង ហើយគាត់បានស្គាល់ជាមួយពួកគេជិតស្និទ្ធរួចទៅហើយ។

ធុច ថា ចំណុចសំខាន់អំពីអង្គភាពទាំងនេះនៅពេលនេះគឺថា ពួកគេត្រូវបានអង្គការគ្រប់គ្រងដោយផ្ទាល់។ ចាំបាច់ត្រូវប្រុងប្រយ័ត្នឱ្យខ្លាំងអំពីការទាក់ទង និងការនិយាយជាមួយពួកគេ។ [ទំព័រ ៥] គាត់នៅតែមានឥទ្ធិពលខ្លះ ហើយគាត់នឹងប្រើប្រាស់សក្តានុពលនេះ។ នៅពេលដែលការសន្ទនាបញ្ចប់ គ្រប់គ្នាវិលត្រឡប់ទៅមូលដ្ឋានរបស់ខ្លួនវិញ ដោយផ្ទុកក្នុងរថយន្តរបស់ពួកគេនូវថ្នាំពេទ្យជាច្រើន។

បន្ទាប់ពីសមាជលើកទីបួនរបស់មជ្ឈិមបក្ស ធុច ប្រាប់ខ្ញុំថា ប៉ុន្មានថ្ងៃខាងមុខនេះ យើងនឹងធ្វើការរៀបចំរដ្ឋប្រហារហិង្សាភ្លាមៗមួយដើម្បីដណ្តើមយកអំណាចរដ្ឋពីក្បាលម៉ាស៊ីនដឹកនាំ ជាពិសេសក្នុងអំឡុងពេលពិធីបុណ្យនាពេលខាងមុខ។ គាត់ស្នើថា កម្មាភិបាលយើងត្រូវត្រៀមខ្លួនជាស្រេចដើម្បីជួយនៅមូលដ្ឋានជាពិសេសជាមួយនឹងកងកម្លាំងកងទ័ពដែលអាចជួយបាន។ ទោះយ៉ាង នៅពេលជួបគ្នាពេលនេះ គាត់មិនបញ្ជាក់ថាការធ្វើរដ្ឋប្រហារហិង្សាភ្លាមៗបែបណាដែលនឹងកើតឡើងនោះទេ។ ខ្ញុំត្រូវត្រឡប់មកវិញ ហើយចាំមើលសិន។ ទោះយ៉ាងណា ខ្ញុំដឹងពី ឌឿន ថា បញ្ហាសំខាន់គឺត្រូវប្រាកដថាបានកម្ចាត់មេខ្ពស់បំផុតទាំងពីរនៅក្នុងក្បាលម៉ាស៊ីនដឹកនាំ។ ផែនការនេះត្រូវបរាជ័យដោយសារអង្គការបានចាត់វិធានការទប់ស្កាត់ជាមុន។

**Deleted:** Non revised version, portion(s) of this document will be revised by ITU upon request.¶

ក្នុងអំឡុងពេលត្រីមាសដំបូងឆ្នាំ ១៩៧៦ ធុច ត្រូវអង្គការឃុំខ្លួន ដំបូងឡើយដោយសារបញ្ហាសីលធម៌។ ខ្ញុំ និងក្រុមខ្ញុំត្រូវបានកាត់ផ្តាច់ពីខ្សែរយៈទំនាក់ទំនងរបស់យើង។ បញ្ហានេះត្រូវបានដឹងនៅថ្នាក់មូលដ្ឋាន។ គ្រប់សមាជិកគណៈកម្មាធិការទៅជាល្វើយ និងគ្មានកម្លាំងធ្វើការ។ អ្វីដែលគួរឲ្យបារម្ភមួយទៀតគឺ ការបែកការណ៍។ អង្គការនេះអាចដឹងពីខ្សែរយៈរៀបចំរបស់យើង។ ខ្ញុំបាននិយាយទៅកម្មាភិបាលយើងថា យើងគួរតែរក្សាភាពស្ងៀមស្ងាត់មួយរយៈសិន ហើយចាំ ឌឿន ផ្តល់ដំណឹងឱ្យយើងពីការប្រែប្រួលនៃស្ថានភាពរបស់ ធុច និងថាតើយើងត្រូវទាក់ទងការងារយើងជាមួយនរណា។ បញ្ហានេះនៅតែស្ងៀមស្ងាត់មួយរយៈ។ ពីរសប្តាហ៍ក្រោយមក ឌឿន បានផ្តាំថា ពួកគេដឹងថា ពួកយើងបានស្នើសុំអ្នកទំនាក់ទំនងដោយផ្ទាល់។ នោះគឺ យ៉ា នៃភូមិភាគឦសាន ដែលចង់បានការទទួលស្គាល់ជាផ្លូវការផងដែរ។ ស្របពេលនេះដែរ គាត់កំពុងស្នើសុំឱ្យមានការរៀបចំទំនាក់ទំនងជាមួយនឹងតំបន់ ១០៦។

[ទំព័រ ៧]

មានទំនាក់ទំនងម្តងរវាង យ៉ា និងខ្ញុំ មុនពេលដែល យ៉ា ត្រូវឃុំខ្លួន គឺនៅពេលដែលគាត់មកធ្វើការជាមួយអង្គការ។ យ៉ា ថា បញ្ហាសំខាន់ក្នុងការអនុវត្តផែនការ ច្បាស់ណាស់គឺការសម្លាប់ក្បាលម៉ាស៊ីនដឹកនាំពោលគឺបងធំទីមួយ។ ឥឡូវនេះ ផែនការទីមួយត្រូវបែកការណ៍។ ចក្រីដែលទទួលផែនការនេះឥឡូវនេះត្រូវអង្គការឃុំខ្លួន។ ធុច ដែលជាតំណាងរបស់យើង ក៏ត្រូវឃុំខ្លួនផងដែរ។ ហេតុនេះហើយ នឹងមានទំនាក់ទំនងពីរប្រភេទ។ ម្យ៉ាង មានលទ្ធភាពជាមួយគាត់ (យ៉ា)។ ម្យ៉ាងវិញទៀត វាអាចនឹងធ្វើឡើងតាមរយៈ ឌឿន ដោយសារ ឌឿន មានឱកាសច្រើនដើម្បីធ្វើការទំនាក់ទំនងតាមរយៈវិធីសាស្ត្រស្របច្បាប់ និងក្តាប់ស្ថានភាពបានប្រសើរជាងអ្នកដទៃ។ លើសពីនេះទៅទៀត គាត់ជាអនុប្រធាននៃគណៈកម្មាធិការពីមុន។ គាត់ថា គាត់បានធ្វើការរៀបចំដូចគ្នាជាមួយ សុត។ ...

ខ្ញុំថា ខ្សែរយៈដែលខ្ញុំធ្លាប់មាននៅក្នុងអង្គភាពនេះពីមុន ឥឡូវនេះត្រូវបែកការណ៍អស់ហើយ។ ជាពិសេស ហាស់ ត្រូវចាប់ខ្លួន។ អ្នកដទៃទៀតខ្លះក៏ត្រូវចាប់ខ្លួនផងដែរ។ គាត់ថា គ្មានបញ្ហាទេ។ មានកន្លែងផ្សេងទៀតដែលសំខាន់ នោះគឺភូមិភាគបូព៌ា ដែលមានការបម្រុងទុកគ្រប់គ្រាន់បន្ថែមទៀត។ លើសពីនេះ ត្រូវចាំរហូតដល់មានការរៀបចំតាមរយៈតំបន់ ១០៦។ យើងអាចចាំ និងពឹងផ្អែកលើពួកខាងកើត ហើយវាក៏សំខាន់ផងដែរដើម្បីមានទំនាក់ទំនងជាមួយពួកខាងលិចតាមរយៈខ្សែរយៈសេអ៊ីអាដែល ធុច មានទំនាក់ទំនងជាមួយ។ គាត់ថា សុត នឹងដឹងថាពួកគេជានរណា។ ភូមិភាគ និងតំបន់ទាំងឡាយណាដែលនៅចន្លោះអ្នកដទៃគួរតែឈរក្បែរដើម្បីជួយពួកគេជាមួយនឹងកងកម្លាំងផ្ទាល់ និងធ្វើការបំផ្លិចបំផ្លាញបន្ថែមតាមគ្រប់រូបភាព។ ...

Deleted: Non revised version, portion(s) of this document will be revised by ITU upon request.¶

Original EN: 00143676-00143687

[ទំព័រ ៧]

ខ្ញុំសួរថា ឥឡូវនេះតើគាត់គិតយ៉ាងណាពេលដែលកម្លាំងយើងកាន់តែច្រើនត្រូវបែកការណ៍។ យ៉ា ថា គ្មានបញ្ហាទេ ព្រោះថាបាត់ប៉ុណ្ណា នៅសល់ប៉ុណ្ណឹងដែរ។ យ៉ា ថា ត្រូវចាំមើលតើសមមិត្តយើងរៀបចំបែបណា នៅភូមិភាគបូព៌ា ហើយជាពិសេសនៅស្វាយរៀង។ បើមានការផ្ទុះអាវុធតាមគម្រោងពួកគេ យើងគួរតែផ្ទុះអាវុធជាមួយពួកគេដែរ។ ...

...

បកទៅចុងឆ្នាំ ១៩៧៥ បន្ទាប់ពីសមាជលើកទីបួនរបស់មជ្ឈឹមបក្ស ធុច ណែនាំខ្ញុំថា មានវិធីសាស្ត្រជាច្រើនទាក់ទងនឹងការចាប់ផ្តើមការវាយប្រហារដើម្បីដណ្តើមយកអំណាចរដ្ឋមកវិញ។

១. រឿងសំខាន់គឺត្រូវរៀបចំឱ្យមានអំណាចគ្រប់គ្រាន់នៅខាងក្នុង ហើយក្នុងន័យនេះ ត្រូវយកចិត្តទុកដាក់ដល់យោធា។ នេះមានន័យថា យើងនឹងវាយប្រហារពីខាងក្នុងដោយប្រើប្រាស់កម្លាំងយោធា។

២. ការវាយប្រហារពីខាងក្រៅ ជាពិសេសប្រទេសវៀតណាម។ ដរាបណាយើងមានសេចក្តីក្លាហានក្នុងការចាប់ផ្តើមផ្ទុះអាវុធ ពួកគេនឹងមកជួយយើងភ្លាមៗតាមរយៈភូមិភាគបូព៌ា។

៣. យើងនឹងមានទ័ពជំនួយតាមរយៈការទំនាក់ទំនងរបស់យើងជាមួយនឹងពួកខាងលិច តាមរយៈការទំនាក់ទំនងសេអ៊ីអាចាស់របស់យើង តាមរយៈតំបន់ ១០៦ ដែលជាកន្លែងដែលយើងមានការត្រៀមលក្ខណៈជាមុន។

៤. បញ្ហាគន្លឹះសំខាន់គឺត្រូវប្រាកដថាសម្លាប់បងធំទីមួយបាន មិនថានរណាអាចធ្វើវាក៏ដោយ។ យើងក៏មានការត្រៀមលក្ខណៈជាមុនផងដែរនៅត្រង់នេះ។

[ទំព័រ ៨]

នៅក្នុងការវាយប្រហារដំបូង យើងនឹងចាប់ផ្តើមផ្ទុះអាវុធនៅទីក្រុងភ្នំពេញ ក្នុងរបៀបរដ្ឋប្រហារហិង្សា និងកម្ចាត់ក្បាលម៉ាស៊ីនដឹកនាំចោល។ ក្នុងអំឡុងពេលនេះ យើងនឹងវាយប្រហារ និងរំដោះភូមិភាគបូព៌ាទាំងមូលឡើងទៅភូមិភាគពាយ័ព្យ... 

Original EN: 00143676-00143687

Deleted: Non revised version, portion(s) of this document will be revised by ITU upon request.¶

វិធានការនៅទីនោះគ្រប់ពេលដែលយើងចង់។ ទោះជាយ៉ាងណា សំខាន់ យើងត្រូវប្រាកដថា យើងបានបង្កើតទំនាក់ទំនងជាមួយនឹងពួកខាងលិចរួចហើយដោយប្រើកម្លាំងសេអ៊ីអារបស់យើង។ (សុត កាន់តួនាទីនេះ)។

ពេលដែលយើងចាប់ផ្តើមការវាយប្រហាររបស់យើង យើងនឹងត្រូវបង្កើតរដ្ឋធានីរបស់យើងផ្ទាល់ដើម្បីធ្វើសកម្មភាពនយោបាយនៅក្រៅប្រទេស ដើម្បីទទួលបានការគាំទ្រពីខាងក្រៅសម្រាប់យើង។ បើយើងអាចយកតំបន់ ១០៦ ហើយពួកខាងលិចជួយយើងការពារវា យើងអាចយកទីរួមខេត្តសៀមរាប ឬប្រាសាទអង្គរវត្តជារដ្ឋធានីរបស់យើង។ បញ្ហាប្រាសាទអង្គរវត្តគឺសំខាន់ណាស់សម្រាប់ជនបរទេស។

សម្រាប់បញ្ហាសម្លាប់បងធំទីមួយវិញ ចាំបាច់ត្រូវមានផែនការអចិន្ត្រៃយ៍នៅគ្រប់តំបន់មូលដ្ឋានដែលយើងមានគ្នាយើង។

ឧទាហរណ៍ យើងត្រូវធ្វើសកម្មភាពគ្រប់រូបភាពនៅទីក្រុងភ្នំពេញ។ ចំពោះថា រឿងនេះស្រួល ឬមិនស្រួលគឺអាស្រ័យលើ ខៀវ ថាតើគាត់ក្លាហានហ៊ានធ្វើសកម្មភាព ឬក៏អត់។ គាត់បានផ្តល់ការណែនាំជាប្រចាំឱ្យ ខៀវ លើបញ្ហានេះ ប៉ុន្តែមិនបានលទ្ធផលជាក់ស្តែងទេ។ គេអាចរៀបចំអង្គភាពសម្ងាត់ដើម្បីសម្លាប់គាត់នៅតាមផ្លូវចេញចូល។

[ទំព័រ ៩]

មានលទ្ធភាពជាច្រើនផងដែរនៅតាមមូលដ្ឋាន ជាពិសេសរាល់ពេលដែលអង្គការទៅចូលរួមសន្និសីទ ឬកិច្ចប្រជុំ ឬក្នុងដំណើរអធិការកិច្ចលើតំបន់មូលដ្ឋាន។ ដរាបណាយើងមានសមត្ថភាពដាក់បញ្ចូលគ្នានូវកម្លាំងស្រួចជាសម្ងាត់ យើងនឹងមានសមត្ថភាពពេញលេញក្នុងការអនុវត្តសកម្មភាពនេះ។

តាមរយៈអ្វីដែលគាត់អាចប្រមូលពីរបាយការណ៍ បញ្ហាគឺថាតើមាននរណាម្នាក់ក្លាហាន ឬក៏អត់។ បញ្ហាខ្វះភាពក្លាហាននៅតែមាន។ នៅតែគ្មានសមមិត្តសូម្បីតែម្នាក់ដែលហ៊ានទាំងស្រុង។ ទោះយ៉ាងណា នេះគឺជាឱកាសដំបូងដែលយើងបានជំរុញផែនការបែបនេះ។ នេះក៏មិនមែនជារឿងម្តងចប់នោះដែរ។ វាគឺជាផែនការយុទ្ធសាស្ត្រ។ បើយើងមិនជោគជ័យនៅឆ្នាំ ១៩៧៦ យើងនឹងបន្តនៅឆ្នាំបន្តបន្ទាប់ទៀត។

លើសពីនេះ ចាំបាច់ត្រូវដាក់បញ្ចូលគ្នា [សន្តិសម្ព័ន្ធ] នូវកម្លាំងដើម្បីធ្វើចលនាឃាយីដើម្បីបង្កើតផលវិបាកតាមមូលដ្ឋាន និងអង្គភាពរបស់អង្គការ ដោយបង្កើតជាសភាពចលាចល និងភាពច្របូកច្របល់គ្រប់រូបភាពពាក់ព័ន្ធនឹងរឿងផ្សេងៗជាច្រើន។ មានសមត្ថភាពពេញលេញសម្រាប់ធ្វើសកម្មភាពនេះនៅតាមមូលដ្ឋាន។

បញ្ហាសំខាន់ដែលទាក់ទងទៅនឹងការអនុវត្តមាគ៌ានយោបាយបក្សកុម្មុយនីស្តកម្ពុជា ដោយអនុលោមទៅតាមគោលនយោបាយរបស់យើង គឺយើងមិនធ្វើការឃោសនាប្រឆាំងចេញមុខ ឬចេញមុខលើកបញ្ហាជាទំនាស់

Deleted: Non revised version, portion(s) of this document will be revised by ITU upon request.¶

ទេ។ យើងមិនអាចធ្វើអ្វីៗក្នុងរយៈពេលវែងតាមវិធីនេះទេ។ រឿងសំខាន់គឺថា យើងដឹងពីរបៀបដើម្បីដកចេញដោយស្របច្បាប់ពីមាគ៌ានយោបាយ។

ឧទាហរណ៍ នៅក្នុងការដាក់សហករណ៍ជនបទរួមគ្នា យើងនឹងណែនាំថា រឿងនេះគឺត្រូវធ្វើស្របតាមមាគ៌ានយោបាយ ប៉ុន្តែដោយមិនខ្វល់ថាតើរឿងនេះអាចទៅរួច ឬក៏អត់ យើងមិនគួរប្រើការបង្ខិតបង្ខំឡើយ។ យើងគួរតែធ្វើអ្វីក៏ដោយឲ្យតែអាចធ្វើទៅបានដើម្បីពន្យឺតរឿងទាំងអស់។

[ទំព័រ ១០]

វិធីសាស្ត្រមួយផ្សេងទៀតគឺ "ដុតវាឲ្យទាល់តែផុយនៅខាងក្រៅ តែទាញវាចេញពេលដែលវានៅនៅខាងក្នុង"។ វិធីសាស្ត្រនេះបង្កើតបរិយាកាសប្រជាជនស្មុគស្មាញដែលមិនធ្លាប់មានបន្ថែមទៀតទាក់ទងទៅនឹងមាគ៌ានយោបាយបក្ស។ ដូច្នេះ ស្ថានភាពនេះនឹងជារឿងល្អសម្រាប់យើង។ គ្មានចំណុចណាមួយនៃរឿងនេះគឺជាចំណុចសំខាន់នៃបញ្ហា ពោលគឺត្រូវដណ្តើមយកអំណាចរដ្ឋទេ ដោយហេតុថាវានៅក្នុងកណ្តាប់ដៃយើង ឬ នៅក្នុងកណ្តាប់ដៃរបស់អ្នកដែលនៅក្នុងក្រុមរបស់យើងរួចទៅហើយ ដោយប្រើទាំងវិធីសាស្ត្រហិង្សា និងអហិង្សា។

...

ដូច្នេះ ទោះជា ធុច ត្រូវឃុំខ្លួនហើយក៏ដោយ ហើយទំនាក់ទំនងនៅពេលនេះត្រូវបានបង្កើតឡើងជាមួយនឹង យ៉ា ក៏ការអនុវត្តផែនការនេះជាគោលការណ៍គឺនៅដដែលដូចមុន។ ក្នុងអំឡុងឆ្នាំ ១៩៧៦ គោលការណ៍នៃផែនការខាងលើនេះត្រូវបរាជ័យម្តងហើយម្តងទៀត។

បន្ទាប់ពីផែនការរបស់ ចក្រី ត្រូវបែកការណ៍ យ៉ា អស់សង្ឃឹមជាខ្លាំង។ គាត់ប្រាប់ សុត ថា កម្លាំងស្រួចដ៏សំខាន់នៅពេលនេះត្រូវបំផ្លាញចោល ហើយលើសពីនេះ ទំនងថា ឥឡូវនេះ អណ្តាតភ្លើងត្រូវបញ្ឆេះហើយវានឹងរីករាលដាលដូចភ្លើងឆេះព្រៃដែរ។

សុត សួរគាត់ថា ឥឡូវនេះតើគាត់គិតបែបណាដែរ។ យ៉ា តបថា ដំបូង គាត់នឹងសួរអ្នកដែលនៅភាគខាងត្បូងអំពីអ្វីដែលគួរតែធ្វើនៅពេលនេះ។ បន្ទាប់មក យ៉ា សួរ សុត ថាតើគាត់បានបង្កើតទំនាក់ទំនងជាមួយពួកខាងលិចហើយឬនៅ ជាពិសេសជាមួយនឹងកងកម្លាំងសេអ៊ីអាចាស់របស់ ធុច។ សុត ថា គាត់មិនទាន់អាចធ្វើបែបនេះទេ ព្រោះគាត់ជាប់រវល់ខ្លាំងជាមួយនឹងប្រជាជនដែលគ្មានបាយហូប។ គាត់ក៏មមាញឹកខ្លាំងក្នុងការបង្កើតផែនការជាប្រព័ន្ធមួយដើម្បីធ្វើឲ្យរឿងទាំងអស់ស្មុគស្មាញផងដែរ។ ដូច្នេះ យើងនឹងត្រូវចាំមើលថាតើទីបញ្ចប់នឹងទៅជាយ៉ាងណា។

[ទំព័រ ១១]

Formatted: Condensed by 0.7 pt

Deleted: Non revised version, portion(s) of this document will be revised by ITU upon request.¶

លើសពីនេះ យ៉ា បានណែនាំ សុត ឱ្យខ្ញុំគ្រប់បែបយ៉ាងដើម្បីឱ្យប្រាកដថា យើងរកឃើញច្រកចេញជាច្រើនដើម្បីធ្វើទំនាក់ទំនងទៅខាងក្រៅបាន។ បើមិនដូច្នោះទេ យើងនឹងមានគ្រោះថ្នាក់ ហើយយើងនឹងមិនអាចរកនរណាម្នាក់ឱ្យជួយយើងបានឡើយ។ សុត បាននិយាយបែបកំប្លែងថា បើវាគ្រាន់តែជាបញ្ហានៃការរកច្រករត់ចេញមែននោះ ដោយសារថាមនុស្សជាច្រើនអាចទៅតាមចង់ នៅពេលណាដែលពួកគេចង់។ ដូច្នេះគាត់មិនគួរបារម្ភទេ ...

ពេលវេលានៃកិច្ចប្រជុំនេះគឺនៅចុងខែ កក្កដា និងដើមខែ សីហា ឆ្នាំ ១៩៧៦ ពេលដែលអង្គការបានកោះប្រជុំដើម្បីរៀបចំបង្កើតផែនការរយៈពេលបួនឆ្នាំជាប្រព័ន្ធរបស់បក្ស។ ក្នុងឱកាសនេះ ឈូក បានក៏ចូលរួមកិច្ចប្រជុំនេះផងដែរ។ ចាប់ពីពេលនោះមក ទឹកមុខរបស់ ឈូក មិនមានភាពរីករាយទេ។

នៅពេលដែលកិច្ចប្រជុំនេះបញ្ចប់ ហើយគ្រប់គ្នាវិលត្រឡប់ទៅមូលដ្ឋានរបស់ខ្លួនវិញ យ៉ា បានណែនាំ ឌឿន ថា នៅឱកាសដែលយើងត្រូវមកធ្វើការនៅខែ កញ្ញា ឆ្នាំ ១៩៧៦ គាត់គួរតែណែនាំ ស្រេង និង សុត ឱ្យធ្វើសកម្មភាពនៅថ្នាក់មូលដ្ឋានក្នុងន័យបង្កើតឱ្យមានជាស្ថានភាពច្របូកច្របល់។ ឌឿន ពិតជាបានមកណែនាំខ្ញុំបែបនោះមែន។

នៅដើមខែ កញ្ញា ឆ្នាំ ១៩៧៦ មុនពេលដែលយើងបានចូលរៀននៅសាលាបក្ស សុត ឱ្យខ្ញុំដឹងពីអ្វីដែលគាត់បានដឹងពី ឌឿន ថា អង្គការឥឡូវនេះបានឃុំខ្លួន ឈូក នៅភូមិភាគបូព៌ា ហើយគាត់ស្នើថា យើងត្រូវប្រុងប្រយ័ត្នចំពោះការត្រៀមលក្ខណៈជាមុន។ ទោះយ៉ាងណា គាត់មិនបានជំរុញគោលនយោបាយនេះទេ។ បន្ទាប់មក នៅចុងខែ កញ្ញា ឆ្នាំ ១៩៧៦ យ៉ា ក៏ត្រូវឃុំខ្លួនផងដែរ។ នេះគឺជាព្រឹត្តិការណ៍ដែលបង្កឱ្យមានការភិតភ័យជាពិសេសនៅពេលដែលទំនាក់ទំនងរបស់ភូមិភាគឧត្តរឥឡូវនេះបានបែកការណ៍យ៉ាងច្បាស់ក្រឡែត។
[ទំព័រ ១២] ក្រុមខ្ញុំទៅជាបាក់កម្លាំងចិត្តជាខ្លាំង មិនត្រឹមតែដោយសារការបាត់បង់នៃក្បាលម៉ាស៊ីនដឹកនាំដ៏សំខាន់ប៉ុណ្ណោះទេ តែក៏ដោយសារតែយើងខ្លួនឯងក៏ប្រហែលជាត្រូវប្រឡូកប្រឡាក់ និងមិនដឹងថាត្រូវដោះស្រាយបញ្ហានោះដោយរបៀបណាផងដែរ។

ខ្ញុំបានជួប សុត និងជជែកជាមួយគាត់អំពីគំនិតដែលយើងមាន។ សុត ថាឱ្យផ្អាកសកម្មភាពសិនរហូតដល់យើងសួរ ឌឿន សិន។ មួយរយៈនេះ យើងគួរតែឱ្យ ឌឿន ក្ដាប់ស្ថានភាពបន្តិចម្តងៗសិន។ បើមានអ្វីខុសពីការរំពឹងទុក ហើយសុវត្ថិភាពរបស់យើងលែងអាចធានាបានទៀត នោះមានលទ្ធភាពតែមួយគត់សម្រាប់ដំណោះស្រាយបន្ទាន់ នោះគឺត្រូវរៀបចំដើម្បីរត់គេចខ្លួនទៅជ្រកកោននៅប្រទេសសៀម និងបន្ទាប់មក នៅពេលដែលយើងទៅដល់ទីនោះ យើងនឹងត្រូវរិះរកថាតើត្រូវធ្វើអ្វីបន្ទាប់មកទៀត។ ខ្ញុំប្រាប់គាត់ថា គាត់ក្ដាប់



Deleted: Non revised version, portion(s) of this document will be revised by ITU upon request.¶

តំបន់ ១០៦ បានហើយ។ តើមានរឿងអ្វីកើតឡើង បើយើងប្រកាសថា យើងបានកាន់កាប់កន្លែងនេះ និងធ្វើឱ្យវាក្លាយទៅជារដ្ឋមួយ? សុត ថា តើយើងអាចធ្វើដូចនេះបានដោយខ្លួនឯងយ៉ាងម៉េចទៅ? យើងមិនបានបង្កើតទំនាក់ទំនងជាមួយនឹងពួកខាងលិចរហូតដល់ថ្នាក់យើងស្គាល់គ្នាជិតស្និទ្ធទេ។ ការបម្រុងទុករបស់យើងនៅ_ទីនោះមិនរឹងមាំដូចការបម្រុងទុកនៅខាងកើតដែរ ដោយសារតែទំនាក់ទំនងទៅនឹង ខាងកើតគឺជាទំនាក់ទំនងចាស់តាំងពីក្នុងសម័យអាណានិគមបារាំងមកម្ល៉េះ។ ការពិភាក្សារកច្រកចេញមិនឃើញ ហើយយើងកាន់តែស្មុគស្មាញឡើងរហូតដល់ហួបបាយមិនចូល។

ខណៈពេលសម្រាករបៀបចំសម្រាប់វគ្គទស្សនវិស័យជីវិតនៅសាលាបក្ស ខឿន ខ្ញុំ និង សុត រកបានឱកាសជួបគ្នា ... នៅភាគខាងលិចនៃព្រះវិហារកែវ ...ដែលជាកន្លែងរបស់សាលានៅពេលនោះ។

ខឿន ថា ឥឡូវនេះខ្សែរយៈយើងត្រូវបែកការណ៍ធំហើយ។ បើ យ៉ា សារភាពបែបនោះមែន រឿងពិតជាទៅដល់ ធុច។ (បច្ចុប្បន្ន អង្គការនៅតែគិតថា ធុច មិនមែនជាខ្មាំងទេ)។ បន្ទាប់មក បើ ធុច ក៏សារភាពដែរនោះខ្សែរយៈរបស់ភូមិភាគឧត្តរពិតជាត្រូវបែកការណ៍ ហើយខ្សែរយៈបែបនេះមានច្រើនណាស់។
[ទំព័រ ១៣]

ឥឡូវនេះ ចាំបាច់យើងត្រូវរកវិធីមួយចំនួន។ អ្វីដែលគាត់ (ខឿន) គិតគឺ៖

១. យើងអាចបន្តតួនាទីរបស់យើងបានក្នុងវិសាលភាពតូចចង្អៀត។

២. យើងគួរតែនៅឱ្យស្ងៀម ប៉ុន្តែការនៅស្ងៀមបែបនេះនឹងមិនអាចធានានូវការការពារដល់កម្លាំងយើងបានទេ។

៣. អាចមានលទ្ធភាពរត់គៀសខ្លួនទៅបរទេស។

កម្លាំងយោធាយើងឥឡូវនេះបានចុះខ្សោយយ៉ាងខ្លាំងរួចទៅហើយ។ អង្គការបានកាត់ដៃកាត់ជើងវាចោលហើយ។ គាត់មិនបានក្តាប់ស្ថានភាពនោះបានច្រើនទេ (ខឿននិយាយ) ព្រោះគាត់ត្រូវជាប់គាំងនៅក្នុងការិយាល័យ ៨៧០។ ក្នុងកម្រិតនៃអ្វីដែលនៅសល់ ពីអ្វីដែល ធុច បានឱ្យគាត់ដឹង ពួកគេមិនបានចាប់អារម្មណ៍ខ្លាំងដូច ចក្រី នោះទេ។ ទោះយ៉ាងណា បើយើងនឹងធ្វើអ្វីរបៀបនោះ [សន្តិសម្ព័ន្ធ] នោះគឺអាចទៅរួច។

ឧទាហរណ៍ នៅក្នុងកងពលធំលេខ ៣១០ ពួកគេបានបង្កើតក្រុមកងកម្លាំងវេជ្ជសាស្ត្រមួយដើម្បីបំផ្លាញជីវិតរបស់កម្មាភិបាល និងយុទ្ធជនដែលកំពុងតែគោរពតាមបក្សក្នុងការធ្វើបដិវត្តន៍។ ...

Deleted: Non revised version, portion(s) of this document will be revised by ITU upon request.¶

... គាត់ងាកមករកខ្ញុំ ហើយសួរខ្ញុំថា តើមានអ្វីកើតឡើងចំពោះកម្លាំងកងទ័ពនៅកន្លែងដែលខ្ញុំកំពុងឈរជើង។ ឥឡូវនេះ ពេលដែល ហា បានទៅបាត់ហើយ តើអ្នកណាដែលនៅសល់? ខ្ញុំតបវិញថា មាននៅសល់មួយចំនួន ប៉ុន្តែពួកគេមិនមែនសាហាវដូច ហា នោះទេ។ អ្នកដែលនៅសល់ដែល ហា ជឿទុកចិត្ត មានដូចជា៖

១. ដួង កងវរសេនាធំ ឥឡូវនេះត្រូវឃុំខ្លួន

២. ឡៃ កងវរសេនាតូច ឥឡូវនេះត្រូវឃុំខ្លួន

៣. ស្មៅ កងវរសេនាតូច ឥឡូវនេះត្រូវឃុំខ្លួន

[ទំព័រ ១៤]

៤. គុច (ផ្នែកភស្តុភានៃកងពលធំឈរជើងនៅកំពង់ធំ) មិនទាន់ត្រូវឃុំខ្លួននៅឡើយទេ

៥. ហាំ កងវរសេនាធំ មិនទាន់ត្រូវឃុំខ្លួននៅឡើយទេ។ ហាំ ត្រូវ ហា បញ្ចុះបញ្ចូលបាន បន្ទាប់ពីការរំដោះទូទាំងប្រទេស ដោយផ្អែកលើមនោសញ្ចេតនាដោយសារតែពួកគេជាមិត្តភក្តិជិតស្និទ្ធកាលពីសម័យមុន។

...

ទាក់ទងទៅនឹងគោលបំណងព្យាករថ្មី យើងព្រមព្រៀងគ្នាថា ចាំបាច់ត្រូវបន្តសកម្មភាព ប៉ុន្តែអ្វីដែលកាន់តែសំខាន់ជាងនោះគឺមិនត្រូវធ្វើដូច្នេះទេរហូតដល់យើងបានរៀបចំសម្រាប់ការបម្រុងទុក។ បញ្ហានេះគឺអាស្រ័យលើ សុត ដែលមានលទ្ធភាពធំជាងគេ។ សុត បានកាត់សម្តីភ្លាមដើម្បីនិយាយថានេះមិនអាចទ្រទ្រង់ចលនាបែបនេះបានទេ។ មើលបទពិសោធន៍របស់ឈូកទៅ៖ គាត់មានទំនាក់ទំនងជាប្រចាំចាប់តាំងពីសម័យមុន ដូច្នេះហេតុអ្វីបានជាមិនអាចគាត់រត់រួច? ដូច្នេះ យើងមិនគួរចាប់លេងភ្លាមៗទេ។ វាត្រូវការពេលយូរមុនពេលដែលវាអាចទៅរួច នៅពេលដែលយើងបានបង្កើតទំនាក់ទំនងល្អ។ ការពិភាក្សារកច្រកចេញមិនឃើញ។ ...

ក្រោយមក យើងបានជួបគ្នាម្តងទៀតនៅកន្លែងដដែល។ ពេលនេះ យើងបានពិភាក្សាអំពីការរៀបចំសម្រាប់ទំនាក់ទំនង និងផែនការសម្រាប់ឆ្នាំ ១៩៧៧។

ទៅតាមស្ថានភាពដែលក្បាលម៉ាស៊ីនដឹកនាំបាត់បង់ទៅហើយ តួនាទីដែលយើងត្រូវបន្តរួមមាន៖

១. សម្រាប់ ខឿន និង សុត វាងាយស្រួលក្នុងការធ្វើអ្វីដោយវិធីសាស្ត្រស្របច្បាប់ ដោយសារ សុត បានគ្រប់គ្រងតំបន់ឯករាជ្យ។ ស្រេង គឺមិនឯករាជ្យទេ ដូច្នេះវាមិនសមរម្យទេសម្រាប់ខ្ញុំដែលត្រូវធ្វើដំណើរទៅមក ព្រោះរឿងនេះនឹងធ្វើឲ្យបែកការណ៍ ហើយធ្វើឱ្យមហាជនសង្ស័យ។ ទោះយ៉ាងណា បើមានអ្វីមួយពិសេសត្រូវចាត់ការ នោះគ្មានបញ្ហាកើតឡើងទេ។ នេះជារឿងមួយ។ រឿងមួយទៀតនោះគឺថា ស្រេង អាចទាក់ទង

Deleted: Non revised version, portion(s) of this document will be revised by ITU upon request.¶

ជាមួយ សុត។ យើងអាចចាំរហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ [ខុស? គួរតែខែ ធ្នូ ឆ្នាំ ១៩៧៦?] នៅពេលដែលយើងជួបគ្នាជាថ្មីទៀតនៅកន្លែងដែលត្រូវធ្វើការងារ។ នេះគឺបើស្ថានភាពនៅតែអនុញ្ញាតឱ្យពួកយើងបានជួបគ្នាដោយសារយើងគ្រប់គ្នានឹងត្រូវមមាញឹកជាមួយនឹងការកោះប្រជុំរបស់សាលានៅក្នុងតំបន់ និងភូមិភាគ។

ដល់ពេលសន្និសីទបក្សប្រចាំឆ្នាំ នៅឆ្នាំ ១៩៧៦ យើងបានជួបគ្នាតាមការគ្រោងទុក។ ... ការពិភាក្សាបានយល់ស្របលើគោលនយោបាយចំនួនបី៖

១. មានការស្នើឡើងថា សុត ត្រូវប្រាកដថា គាត់បានបង្កើតទំនាក់ទំនងជាមួយនឹងពួកខាងលិច និងតាមរយៈអន្តរការិយកម្មបែបនេះផងដែរ សូមបង្កើតទំនាក់ទំនងជាមួយនឹងខ្សែរយៈចាស់របស់ ធុច ពោលគឺខ្សែរយៈសេរីអា។ មានតែដូច្នេះទេ ទើបយើងអាចទទួលបានជំនួយ។

២. រៀបចំសម្រាប់ការផ្គត់ផ្គង់ស្បៀង និងផ្លូវដើម្បីទៅដល់តំបន់ ១០៦។ ស្រេង ជាអ្នកទទួលខុសត្រូវលើបញ្ហានេះ។ ផ្លូវសំខាន់គឺទន្លេសាបដែល ជិន ត្រូវម្ចាស់ការឲ្យបាន។ ផ្លូវនេះក៏ជាផ្លូវស្របច្បាប់បំផុត និងជាផ្លូវដែលទុកចិត្តបានបំផុត។

គ្រប់គ្នាបានយល់ព្រមលើផែនការនេះ ប៉ុន្តែ វាត្រូវបានគូសបញ្ជាក់ថា តួនាទីនៅឆ្នាំ ១៩៧៧ ទាំងនេះមិនមានលក្ខណៈជាការវាយប្រហារសម្រុកទេ។ ផ្ទុយទៅវិញ ពួកគេបានរៀបចំការត្រៀមលក្ខណៈជាមុនសម្រាប់ការរត់គេចទៅប្រទេសសៀម។ ហេតុផលសម្រាប់រឿងនេះរួមមាន៖

១. ក្បាលម៉ាស៊ីនដឹកនាំសំខាន់បំផុតរបស់យើងត្រូវបានកម្ចាត់ និងរំលាយចោល។

២. ចន្ទល់របស់យើងនៅភូមិភាគបូព៌ាក៏រងការបំផ្លិចបំផ្លាញផងដែរ [ទំព័រ ១៦] ខណៈដែលមិនទាន់មានចន្ទល់ថ្មី ដូចជាពួកខាងលិចត្រូវបានទាក់ទងដោយជោគជ័យនៅឡើយ។

៣. ស្ថានភាពនេះគឺវិលវល់ទាក់ទិននឹងការបែកការណ៍នៃខ្សែរយៈក្បត់របស់យើង ហើយយើងមិនទាន់រកឃើញដំណោះស្រាយចំពោះរឿងនេះទេ។ ខ្សែរយៈទាំងខាងលើ និងខាងក្រោមត្រូវបែកការណ៍ទាំងនៅក្នុងយោធា និងនៅមូលដ្ឋាន។

៤. ឥឡូវនេះ បក្សមានបទពិសោធន៍ក្នុងរឿងបែបនេះ និងអាចយល់ពីស្ថានការណ៍យើង។ ដូច្នេះ យើងត្រូវបង្ខំឱ្យកាន់តែតូចចង្អៀតរហូតដល់យើងស្ទើរតែមិនអាចជួបប្រជុំគ្នាបាន។ បន្ទាប់មក យើងត្រូវបានគេបំបែករហូតដល់ថ្ងៃដែលខ្ញុំត្រូវអង្គការឃុំខ្លួននៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៧។ នៅចុងខែ មករា ឆ្នាំ ១៩៧៧ យើងពិតជាបានជួបគ្នាមួយភ្លែតនៅការិយាល័យភូមិភាគឧត្តរ។ នេះគឺនៅក្នុងឱកាស ដែល ខៀវ មកជួបអង្គការនៅទីនោះ។ យើងមិនបាននិយាយគ្នាទេ ដោយសារគ្មានពេល។

Deleted: Non revised version, portion(s) of this document will be revised by ITU upon request.¶

Original EN: 00143676-00143687

ទាក់ទិននឹងការបំបះបំបោរកងកម្លាំងនៅក្នុងទីក្រុងភ្នំពេញក្នុងអំឡុងពេលឆ្នាំ ១៩៧៧។

១. រឿងនេះត្រូវបានធ្វើឡើងតាមរយៈខ្សែរយៈពាណិជ្ជកម្ម ក្នុងនោះ ឈឿន នឹងជាចំណុចស្នូល។ នេះជាអ្វីដែល ខឿន បានប្រាប់ខ្ញុំ។ អ្វីដែលសំខាន់គឺត្រូវបំផ្លាញកន្លែងស្តុកក្នុងរបៀបបំផ្លិចបំផ្លាញ។

២. វាមុខជាត្រូវធ្វើឡើងដោយកងពលធំភូមិភាគឧត្តរដែលដឹកនាំដោយ អឿន រឿង និង សួង។ គោលបំណងសំខាន់របស់ពួកគេគឺតម្រង់អាវុធទៅបងធំនៅក្នុងជួរថ្នាក់ដឹកនាំ និងយកប្រព័ន្ធឃោសនា។ ការកំណត់ពេលវេលានេះមិនថេរទេ។ រឿងសំខាន់គឺត្រូវក្តាប់ពេលដែលបងធំជួបគ្នា។ នេះគឺជារបៀបរដ្ឋប្រហារហិង្សាភ្លាមៗ។ ត្រង់ថារឿងនេះអាចធ្វើទៅបាន ឬមិនបានគឺជារឿងមួយទៀត។ នេះត្រូវជំរុញជាផែនការបឋមប៉ុណ្ណោះ។ បើវាបែកការណ៍ យើងទាំងអស់នឹងរត់ទៅតំបន់ ១០៦ ដែលយើងនឹងប្រើជាការបម្រុងទុករបស់យើង។

តាមអ្វីដែលខ្ញុំបានដឹងពី ខឿន វានឹងមានការលំបាកក្នុងការអនុវត្តផែនការនេះ។ លទ្ធភាពបានស្មើថាវានឹងមិនដំណើរការឡើយ។ នេះគឺដោយសារនេះជាបច្ចេកទេសចាស់របស់ ចក្រី។ កងកម្លាំងទាំងនេះតាមពិតទៅក៏មិននៅក្នុងទីក្រុងដែរ។ [គាត់និយាយថា??] កងទ័ពកំពុងធ្វើការនៅក្នុងទីក្រុង។ ...

[ទំព័រ ១៧៖ បាត់]

[ទំព័រ ១៨]

អ្វីដែលសំខាន់អំពីការដកកងកម្លាំងដើម្បីគេចទៅតំបន់ ១០៦ គឺត្រូវដកតែស្នូលសំខាន់ដែលបែកការណ៍ប៉ុណ្ណោះ។ ស្នូលរណាបដែលមិនទាន់បែកការណ៍គួរតែរក្សាទុកសម្រាប់រយៈពេលវែង។

តើមានអ្វីដែលភូមិភាគឧត្តរអាចធ្វើបានអំពីការអនុវត្តផែនការនេះនៅឆ្នាំ ១៩៧៧។ អ្វីដែលសំខាន់សម្រាប់ខ្ញុំគឺត្រូវពង្រឹង និងពង្រីកជួរមន្ត្រីដែលធុញទ្រាន់ពីខាងក្នុងបន្ថែមទៀត ដូច្នេះនឹងមានពួកគេជាច្រើននៅគ្រប់តំបន់មូលដ្ឋាន។

ត្រូវបង្កើតបរិយាកាស [សន្តិសម្ព័ន្ធ] តាមគ្រប់រូបភាពដើម្បីធ្វើឱ្យរឿងកាន់តែស្មុគស្មាញនៅតាមភូមិសហករណ៍ និងការដ្ឋាននានា។

ត្រូវរៀបចំការផ្គត់ផ្គង់ស្បៀងជាស្រេចនៅគ្រប់តំបន់មូលដ្ឋាន។ ទោះយ៉ាងណា ការផ្គត់ផ្គង់ស្បៀងទាំងនេះ មុនពេលពួកវាមកដល់ ពួកវានឹងត្រូវបានប្រមូលដាក់ចូលទៅក្នុងជង្រុកសហករណ៍។ ពួកវានឹងមិនត្រូវបានរក្សាទុកនៅកន្លែងដោយឡែកទេ។ ការពិភាក្សាគឺថា យើងបានគ្រប់គ្រងសហករណ៍ទាំងនេះរួចទៅហើយ ដូច្នេះមិនចាំបាច់មានជង្រុកផ្សេងទៀតទេ ដែលនាំឱ្យបែកការណ៍តែប៉ុណ្ណោះ។ នេះគឺដោយសារបទពិសោធន៍ដែល

**Deleted:** Non revised version, portion(s) of this document will be revised by ITU upon request.¶

រហូតមកដល់ពេលនេះគឺថា រឿងនេះមិនបង្កការលំបាកឡើយ។ ដរាបណាយើងមានស្នូលដែលជារបស់យើង ដែលគ្រប់គ្រងសហករណ៍ទាំងនេះ គ្រប់យ៉ាងត្រូវថែរក្សាយ៉ាងល្អ។

មានការលំបាកកាន់តែច្រើនទាក់ទងទៅនឹងការប្រមូលផ្តុំកម្លាំងយោធា ដោយសារក្បាលម៉ាស៊ីនដឹកនាំជាច្រើនត្រូវឃុំខ្លួន ... លទ្ធភាពក្នុងការធ្វើអ្វីមួយគឺមាននៅក្នុងតំបន់ ៤១ ជាកន្លែងដែល កែវ ដែលពីមុនជាអនុប្រធានវរសេនាតូចតំបន់ ដែលមិនទាន់បែកការណ៍នៅឡើយ។ ...

ទាក់ទិនទៅនឹងអង្គភាពចល័ត យើងអាចពឹងផ្អែកលើ ហាំ។ (ហាំ ជាកងវរសេនាធំនៃកងពលធំភូមិភាគឧត្តរ) ហើយគាត់មិនទាន់ត្រូវឃុំខ្លួននៅឡើយ។

...

[ទំព័រ ២០]

<u>ចំពោះសមាសធាតុកងទ័ពនៃកងពលធំ ១០៦</u> ដែលបានចូលរួមនៅក្នុងសកម្មភាពក្បត់បក្ស ...៖

១. ហឿន ជាប្រធានកងពលធំតំបន់ ១០៦ ...

២. ប៉េង ដែលកាន់តំណែងជាសមាជិកកងពលធំ និងគ្រប់គ្រងកងវរសេនាធំលេខ ១ ...

[ទំព័រ ២៧]

ក្រោយថ្ងៃរំដោះទូទាំងប្រទេស ទំនាក់ទំនងជាមួយជនជាតិវៀតណាម ឈ្មោះ បា តឹង ត្រូវបានកាត់ផ្តាច់ ដោយសារនៅពេលនោះមានភាពច្របូកច្របល់ និងការជម្លៀសប្រជាជនជាច្រើន។ ដូច្នេះ នៅឆ្នាំ ១៩៧៥ ខ្ញុំបានសួរ ធុច ពីរឿងនេះ។ គាត់ថា បន្ទាប់ពីការរំដោះភ្នំពេញ បា តឹង បានសរសេរលិខិតមួយមកឱ្យគាត់ ដែលថា ផែនការគឺថា ទំនាក់ទំនងគឺត្រូវបានធ្វើឡើងតាមរយៈ យ៉ា ហើយថាបើ យ៉ា មិននៅភូមិភាគឦសាន នោះសូមទាក់ទងតាមរយៈភូមិភាគបូព៌ា។

ក្នុងឆ្នាំ ១៩៧៦ យ៉ា បានទៅភូមិភាគឦសានធ្វើជាលេខាធិការភូមិភាគ។ យ៉ា បានរៀបចំសម្រាប់ទំនាក់ទំនងជាមួយនឹងពួកវៀតណាមដោយប្រើវិធីសាស្ត្រស្របច្បាប់។ គណៈកម្មាធិការទំនាក់ទំនងត្រូវបានបង្កើតឡើងនៅតាមបណ្តោយព្រំដែន។

នៅខែ មេសា ឆ្នាំ ១៩៧៦ យ៉ា បានអញ្ជើញខ្ញុំទៅលេងក្រចេះនៅការិយាល័យរបស់គាត់។ ខ្ញុំបានឆ្លៀតពេលខ្លះទៅ។ ពេលដែលខ្ញុំបានទៅដល់ខាងលើចូលទៅក្នុងផ្ទះរបស់គាត់ ខ្ញុំបានឃើញជនជាតិវៀតណាមបួននាក់ ក្នុងនោះមាន បា តឹង ផងដែរ ... យ៉ា ថា ពួកគេមកជួយពួកយើង ហើយថា ពួកគេមកទីនោះស្របច្បាប់ ប៉ុន្តែគុណសម្បត្តិនោះកំពុងយកឱកាសនេះដើម្បីរួមគ្នាបង្កើតភារកិច្ចរបស់យើង។

**Deleted:** Non revised version, portion(s) of this document will be revised by ITU upon request.¶

Original EN: 00143676-00143687

ការសន្ទនានេះគ្របដណ្តប់ផែនការដើម្បីវាយប្រហារ និងដណ្តើមយកអំណាចរដ្ឋពីបក្សកុម្មុយនីស្តកម្ពុជា។ ពួកវៀតណាមថា ផែនការដំបូងដើម្បីចាប់ផ្តើមការវាយប្រហារសម្រុកដើម្បីសម្រេចបាននូវការដណ្តើមយកទីក្រុងភ្នំពេញភ្លាមៗ ឥឡូវនេះបានបរាជ័យហើយ។ [ទំព័រ ២៨] ទោះយ៉ាងណា ឥឡូវនេះ យើងកំពុងរៀបចំផែនការមួយទៀត ដែលតាមផែនការនេះ យើងនឹងជំរុញឱ្យមានចលនាដើម្បីវាយប្រហារនៅតាមតំបន់ដែលជាប់ព្រំដែនជាមួយប្រទេសវៀតណាម ហើយបន្ទាប់មកឈានពីពួកវាដើម្បីវាយប្រហារតំបន់ដែលមាននៅផ្នែកកណ្តាលនៃប្រទេសនេះ និងតំបន់កាន់តែជ្រៅថែមទៀត។ ពួកគេថា ពួកគេនឹងជួយជាកងទ័ព និងឧបករណ៍ ឲ្យតែពួកយើងផ្តួចផ្តើមរឿងនេះ។ នេះគឺក្នុងន័យដើម្បីយកផលចំណេញខាងនយោបាយអន្តរជាតិ។ វានឹងមិនអាចទៅរួចទេសម្រាប់ពួកគេក្នុងការផ្តល់ជំនួយចេញមុខ ដោយសារពិភពលោកនឹងមិនគាំទ្រយើង ហើយយើងមិនអាចឈ្នះបានទេ ...

... យ៉ា បានប្រាប់ខ្ញុំថា ពួកគេបានធានាថា ពួកគេនឹងផ្តល់ឱ្យយើងនូវអាវុធទាំងអស់ ឲ្យតែយើងខំប្រឹងប្រែង។ ខ្ញុំថា មិនអីទេ ប៉ុន្តែតើខ្ញុំអាចដឹកអាវុធទាំងនោះតាមរបៀបណា។ យ៉ា ថា គ្មានបញ្ហាទេ។

... បន្ទាប់ពី យ៉ា ត្រូវឃុំខ្លួន សកម្មភាពទំនាក់ទំនងបានស្ងប់ទៅវិញ ហើយដូចជាខ្ញុំគ្មានសក្តានុពលសម្រាប់សកម្មភាពទាំងនោះទេ។

...

Deleted: Non revised version, portion(s) of this document will be revised by ITU upon request.¶